**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប នៅថ្ងៃទី១១-១២ ខែមេសា ឆ្នាំ២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្តេចមហាមន្ត្រី **គុយ សុផល** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ហ៊ុន ម៉ានី** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការ គ.ជ.ប.អ. មានឋានៈ និងបុព្វសិទ្ធិស្មើ ឧបនាយករដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |

| | | |
|---|---|---|
| ៤-លោកអ្នកឧកញ៉ាមហាកក្តី **គង់ បញ្ញា** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | អនុប្រធាន |
| ៥-លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦-ឯកឧត្តម **ចាយ បូរិន** | រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | អនុប្រធាន |
| ៧-ឯកឧត្តម **ហួត ហាក់** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| ៨-ឯកឧត្តម **នេត្រ ភក្ត្រា** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធាន |
| ៩-ឯកឧត្តម **ប្រាក់ សោភ័ណ** | អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធាន |
| ១០-ឯកឧត្តមសន្តិបណ្ឌិត **យូ ស៊ុនឡុង** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | សមាជិក |
| ១១-លោកជំទាវ **ហ៊ុន ម៉ាណា** | អគ្គនាយិកា នៃអគ្គនាយដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន | សមាជិកា |
| ១២-ឯកឧត្តម **សេង ទៀង** | អនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-ឯកឧត្តម **គង់ សោភ័ណ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-ឯកឧត្តម **ជូ គីមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **ខៀវ ពិសេន** | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** | អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៧-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ នាយសេនាធិការចម្រុះ | សមាជិក |
| ១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩-ឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការនៃបញ្ជាការដ្ឋានកងអង្គរក្ស | សមាជិក |
| ២០-ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ សុផាន់** | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ២១-ឯកឧត្តម **សៀង ឈុនទ្រី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២២-ឯកឧត្តម **ឃី សុវណ្ណរតនា** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៣-ឯកឧត្តម **ឱម គីមស៊ា** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៤-លោកជំទាវ **គីម សេដ្ឋានី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ២៥-ឯកឧត្តម **លី រស្មី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៦-ឯកឧត្តម **ភឹម គុណាវឌ្ឍន៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ២៧-ឯកឧត្តម **សាន់ សាប់អី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២៨-លោកជំទាវ **ឡុងឌី សាន់ណារ៉ា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិកា |
| ២៩-ឯកឧត្តម **សោម រតនា** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |

៣០-ឯកឧត្តម **សាម៉ន បណ្ឌិត្យ** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

៣១-អ្នកឧកញ៉ាកត្តីព្រះស្តេច **ហេង គឹមគុណា** ទីប្រឹក្សាក្រសួងព្រះបរមរាជវាំង សមាជិក

៣២-ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត សមាជិក

**ប្រការ២** ._

គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ រៀបចំ ចាត់ចែង សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីឱ្យដំណើរការនៃការរៀបចំព្រះរាជពិធីប្រព្រឹត្តទៅបានល្អ
- រៀបចំគម្រោងចំណាយផ្សេងៗ នៃដំណើរការក្នុងការរៀបចំព្រះរាជពិធី
- រៀបចំការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ចរាចរណ៍ និងធានាសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ មុន-ក្រោយ ក្នុងពេលប្រារព្ធព្រះរាជពិធី និងតាមផ្លូវឆ្លងកាត់
- ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវជាន់ខ្ពស់ជាតិ អន្តរជាតិ ចូលរួមក្នុងព្រះរាជពិធី
- ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការប្រារព្ធព្រះរាជពិធីឱ្យបានទូលំទូលាយ។

**ប្រការ៣** ._

គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីធានាឱ្យការរៀបចំព្រះរាជពិធីប្រព្រឹត្តទៅបានល្អប្រសើរ។

**ប្រការ៤** ._

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រាបេស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៥** ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ